**ឯកសារស្រាវជ្រាវសង្ខេប**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងនៅក្នុងសភា៖ ស្ថានភាពបច្ចុប្បន្ន និងទស្សនវិស័យ


ស្រាវជ្រាវដោយ៖ កញ្ញា ហេង នីដា

ដោយមានការចូលរួមពី៖ លោក នន់ អស្សាច័ន្ទ



ខែសីហា ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈ ការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើង នាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់ តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


១. សេចក្តីផ្តើម ........................................ 1
២. គោលនយោបាយ ICT ........................................ 2
៣. ការអនុវត្តន៍ ICTនៅក្នុងសភា ........................................ 3
៤. បញ្ហាប្រឈមនៃ ICT ក្នុងព្រឹទ្ធសភា ........................................ 5
៥. សេចក្តីសន្និដ្ឋាន ........................................ 6

## ១. សេចក្តីផ្តើម

បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងបានក្លាយជាឧបករណ៍យុទ្ធសាស្ត្រសំខាន់មួយសម្រាប់ការលើកកម្ពស់ការប្រកួតប្រជែង និងជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច។[1] បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងនេះ បានជួយកាត់បន្ថយចំណាយលើសេវាសាធារណៈស្ទើរតែគ្រប់វិស័យ។[2] ទោះបីជាយ៉ាងណា សភាជាញឹកញាប់បានប្រឈម នឹងបញ្ហានៃការផ្លាស់ប្តូរបច្ចេកវិទ្យាព័ត៌មានទំនើបៗ។ នេះក៏ជាផ្នែកមួយ នៃកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើ ទំនើបកម្ម នៃឧបករណ៍បច្ចេកវិទ្យាព័ត៌មាន (ICT) ទំនើបៗ ដើម្បីគាំទ្រដល់ការបំពេញមុខងារ នីតិបញ្ញត្តិ តំណាង និងការត្រួតពិនិត្យ របស់សភា។

បណ្ណាល័យសភាក្នុងប្រទេសកម្ពុជា នៅក្រោមអគ្គលេខាធិការដ្ឋាននៃសភាទាំងពីរដែលជាកន្លែងសំខាន់សម្រាប់រក្សាទុកឯកសារសភា។[3] បណ្ណាល័យនេះជាមជ្ឈមណ្ឌលឯកសារសំរាប់ គាំទ្រដល់ការស្រាវជ្រាវក្នុងការផ្តល់សេវាជូនសមាជិកសភា បុគ្គលិកសភា និងបើកបម្រើសេវាជូនសាធារណជនផងដែរ។[4] លើសពីនេះទៀត ព្រឹទ្ធសភាកម្ពុជា ជម្រុញឲ្យប្រើប្រាស់បណ្ណាល័យអេឡិចត្រូនិចក្នុងការពង្រីកសេវារបស់ខ្លួនបន្ថែមទៀតសម្រាប់ផ្តល់សេវាទៅឲ្យអតិថិជនរបស់ខ្លួន។

ជារួម សភា បានផ្តួចផ្តើមគំនិតក្នុងការពិនិត្យ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងក្នុងការពង្រីក និងពង្រឹងមុខងារស្នូលទាំងបីរបស់ខ្លួន ( នីតិបញ្ញត្តិ តំណាង និង ការត្រួតពិនិត្យ ) ដើម្បីពង្រឹងតម្លាភាព គណនេយ្យភាព មធ្យោបាយងាយស្រួល ប្រសិទ្ធភាព ក្នុងការផ្សាភ្ជាប់ខ្លួនទៅនឹងមណ្ឌលបោះឆ្នោតរបស់ខ្លួន។ ព្រឹទ្ធសភា បានផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យា (ICT) ទំនើប ដើម្បីជួយសម្រួលដល់ការងារ របស់តំណាងរាស្ត្រ និងគណៈកម្មការសភា។ ការបង្កើតឲ្យមានការប្រើប្រាស់ (ICT) និងការប្រាស្រ័យឆ្លើយឆ្លងក្នុងសភានឹងផ្តល់ឲ្យសមាជិកសភានូវព័ត៌មានដែលគួរឲ្យទុកចិត្ត ដែលធ្វើឲ្យការងារសភាកាន់តែមានប្រសិទ្ធភាព ទំនុកចិត្ត និងតម្លាភាព។

ឯកសារសង្ខេបនេះ បញ្ជាក់ពីតម្រូវការ និងរបៀបប្រើប្រាស់ ICT ក្នុងព្រឹទ្ធសភាកម្ពុជា ដើម្បីពង្រឹងតួនាទី និងមុខងាររបស់ខ្លួន។ គន្លឹះសំខាន់ នៃការរកឃើញតាមរយៈការស្រាជ្រាវ ដើម្បីដោះស្រាយសំនួរស្រាវ-ជ្រាវសំខាន់បួន ដែលបានកំណត់ដោយ អគ្គលេខាធិការព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។ សំណួរទាំងនោះរួមមាន៖

១. តើអ្វីខ្លះ ជាគោលនយោបាយបច្ចុប្បន្ន ដែលទាក់ទងនឹងវិស័យបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លង?

២. តើបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លង បាននឹងកំពុងដោះស្រាយតម្រូវការការងារ អ្វីខ្លះក្នុងព្រឹទ្ធសភា?

៣. តើបណ្ណាល័យមានតួនាទីយ៉ាងដូចម្តេចនៅក្នុងព្រឹទ្ធសភា?

៤. តើមានបញ្ហាប្រឈមអ្វីខ្លះ នៅក្នុងការអនុវត្តបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងក្នុងព្រឹទ្ធសភា?

## ២. គោលនយោបាយ ICT

ព្រឹទ្ធសភា មិនបានកំណត់ គោលនយោបាយច្បាស់លាស់ណាមួយ លើវិស័យបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លង(ICT)ផ្ទាល់ខ្លួននៅឡើយទេ ប៉ុន្តែសភាបានប្រើប្រាស់គោលនយោបាយរដ្ឋាភិបាលខ្លះៗតាមរយៈផែនការមេលើវិស័យ ICT ឆ្នាំ២០២០ ដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។[5] រាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តគោលនយោបាយលើវិស័យ ICT ដើម្បីធានាថាយន្តការទាំងនោះត្រូវបានអនុវត្ត ដើម្បីរក្សាប្រព័ន្ធសន្តិសុខជាតិ។[6] រាជរដ្ឋាភិបាល បានកំណត់គោល-នយោបាយអាទិភាព ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT ជាតិ រួមមាន៖[7]

- អភិវឌ្ឍ និងបង្កើនមធ្យោបាយងាយស្រួលក្នុងការផ្តល់សេវាបច្ចេកវិទ្យាទូរគមនាគមន៍ និងការផ្សព្វ-ផ្សាយ ដោយបង្កឲ្យមានភាពងាយស្រួល និងមានតម្លៃទាប ជូនប្រជាពលរដ្ឋនៅតាម តំបន់ជនបទ
- ការបង្កើនហេដ្ឋារចនាសម្ព័ន្ធ ICT តាមរយៈការគាំទ្រពីសំណាក់ រដ្ឋាភិបាល និងការផ្តល់ឱកាសដល់វិស័យឯកជន ដើម្បីវិនិយោគលើការអភិវឌ្ឍន៍វិស័យ ICT និង
- បង្កើតឧបករណ៍ជាមូលដ្ឋានរបស់ ICT ដូចជាទិន្នន័យជាសំឡេង សម្រាប់ការទំនាក់ទំនងឥតខ្សែ (wire and wireless) សេវាកម្មទូរគមនាគមន៍ និងការផ្សព្វផ្សាយ ។

ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រប្រាំដូចខាងក្រោម៖[7]

១.រាជរដ្ឋាភិបាលបាន ផ្តួចផ្តើមឲ្យប្រើប្រាស់ ICT
២.រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ឱកាសជូនដល់ពលរដ្ឋទាំងអស់ ដើម្បីចូលរួមប្រើប្រាស់ICT
៣.បង្កើតបរិយាកាសមួយ ដើម្បីឲ្យវិស័យឯកជនបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ ICT នៅថ្នាក់ជាតិ
៤.បង្កើត បរិយាកាសមួយ ដើម្បីភាពងាយស្រួលក្នុងការអនុវត្ត ICT ដើម្បីបង្កើតតម្លៃបន្ថែមទៀត និង
៥.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT ដែលជាតម្រូវការបន្ថែមទៀត ដើម្បីប្រៀបធៀបទៅនឹងបទដ្ឋានអន្តរជាតិ។

គោលនយោបាយ និងសេចក្តីព្រាងច្បាប់ដែលទាក់ទងនឹងវិស័យបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លង រួមមាន៖[7]

❖ សេចក្តីព្រាងគោលនយោបាយ/ច្បាប់

  - គោលនយោបាយជាតិស្តីពី បច្ចេកវិទ្យាព័ត៌មាន[8] និងការប្រាស្រ័យឆ្លើយឆ្លង (ICT) នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (NIDA) និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC)

- ច្បាប់ស្តីពី ទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍[9] (MPTC)
- ច្បាប់ស្តីពី ពាណិជ្ជកម្មអេឡិចត្រូនិច នៃក្រសួងពាណិជ្ជកម្ម (MOC)
- ច្បាប់ស្តីពី ការគ្រប់គ្រងរលកអាកាសវិទ្យុ[10] នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC)
- ច្បាប់ស្តីពី ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត[11] នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) និងអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NIDA)
- ច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល[12] នៃក្រសួងពាណិជ្ជកម្ម (MOC) Mitsui O.S.K Line (Mol) និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (MCFA)

បច្ចុប្បន្ននេះ ទាំងរដ្ឋាភិបាល និងសភា កំពុងតែពិចារណាចំពោះការប្រើបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លង(ICT) សម្រាប់ការភ្ជាប់ទំនាក់ទំនងទៅនឹងប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងគោលបំណងប្រាស្រ័យឆ្លើយឆ្លង ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ។

## ៣. ការអនុវត្តន៍ICT នៅក្នុងសភា

សមាជិកសភា និងរដ្ឋាភិបាលចាប់ផ្តើមមើលឃើញ ពីផលប៉ះពាល់នៃបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លង(ICT) និងប្រព័ន្ធផ្សព្វផ្សាយសង្គមក្នុងការបោះឆ្នោត[13] និងកំណើននៃសភាអេឡិចត្រូនិច រដ្ឋាភិបាលអេឡិចត្រូនិច នៅកម្រិតមូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។[14] សភាកំពុងប្រើបច្ចេកវិទ្យាថ្មី ដើម្បីកសាងទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋតាមរយៈការអនុវត្តបច្ចេកវិទ្យាព័ត៌មានវិទ្យា និងការប្រាស្រ័យឆ្លើយឆ្លង រួមទាំងតម្លៃនៃនិរន្តរភាពសង្គម ដែលពឹងផ្អែកលើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការគោលនយោបាយ ដែលជាលទ្ធផលនៃការចែករំលែកចំណេះដឹង និងការសន្ទនា។ ជាលទ្ធផល (ICT) បានក្លាយជាអាទិភាពចម្បងរបស់សភា ដែលត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងក្នុងការធ្វើផែនការ ការអនុវត្តន៍ និងបង្កើនការវិនិយោគបន្ថែមទៀតលើឧបករណ៍ ICT ។

សភាកម្ពុជា បានចាប់ផ្តើមអភិវឌ្ឍឧបករណ៍ ICT របស់ខ្លួន ដើម្បីគាំទ្រដល់ការងារស្នូលរបស់សភា។ ព្រឹទ្ធសភាបានបង្កើតឲ្យមានលក្ខណៈវិនិច្ឆ័យសំខាន់បី ដើម្បីឲ្យមានប្រសិទ្ធភាពនៃការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។[15] ព្រឹទ្ធសភា បានផ្តល់នូវឧបករណ៍សំខាន់ៗចំនួនបី ដើម្បីគាំទ្រដល់ដំណើរការសភារួមមាន៖

១. គេហទំព័រ[16]៖ គេហទំព័រនេះផ្តល់នូវទម្រង់ទូទៅ សម្រាប់ការតភ្ជាប់សេវាព័ត៌មានទៅនឹងប្រជា-ពលរដ្ឋ។ នៅក្នុងព្រឹទ្ធសភា គេហទំព័រនេះមានមុខងារពីរ៖ មុខងារទីមួយត្រូវបានផ្តល់ព័ត៌មានជាទូទៅ និងមុខងារមួយទៀតគឺផ្តល់ព័ត៌មានអំពីច្បាប់នានា។ គេហទំព័រនេះ ក៏ផ្តល់ព័ត៌មានអំពីសកម្មភាពនានារបស់សភាផងដែរ ។

២. កម្មវិធីទូរស័ព្ទដៃ Mobile Application ( ប្រព័ន្ធប្រតិបត្តិការ Android និង ប្រព័ន្ធប្រតិបត្តិការ IOS)៖ កម្មវិធីអ៊ីនធឺណេត បានរចនាឡើងដើម្បីដំណើរការលើស្មាតហ្វូន និងឧបករណ៍ទូរសព្ទ័ផ្សេងៗទៀត។ ឧបករណ៍ទាំងនេះនឹងបង្កើតភាពងាយស្រួលដល់អ្នកប្រើប្រាស់តាមរយៈការតភ្ជាប់ទៅកាន់សេវាអ៊ីនធឺណិតដែលកាន់តែងាយស្រួលជាងការប្រើប្រាស់តាមរយៈកុំព្យូទ័រលើតុ។ កម្មវិធីទូរស័ព្ទដៃនេះផងដែរក៏ជាផ្នែកមួយ នៃឧបករណ៍ICT ដែលគាំទ្រកម្មវិធីព័ត៌មានព្រឹទ្ធសភា (Senate News application) ។

៣. ព័ត៌មានព្រឹទ្ធសភា[17] (Senate News)៖ ជាកម្មវិធីដែលប្រើក្នុងទូរស័ព្ទស្មាតហ្វូន ដែលមានអត្ថប្រយោជន៍ និងឆាប់រហ័សជាងគេហទំព័រ។ កម្មវិធីនេះមានភាពងាយស្រួលចូលទៅក្នុងសារ-ព័ត៌មាន ទាក់ទងទៅនឹងសកម្មភាព របស់សមាជិកសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

សភាកម្ពុជា ក៏ផ្តល់នូវសេវាគាំទ្របន្ថែមទៀតដូចជា អ៊ិនធឺណេត អ៊ិនត្រាណេត និងបណ្ណាល័យអេឡិចត្រូនិច ដូចខាងក្រោម៖

- អ៊ិនធឺណេត[18]៖ គឺជាសេវាកម្មសំខាន់បំផុត សម្រាប់ជួយសម្រួលដល់ការងារនៅក្នុងព្រឹទ្ធសភា។ សេវាកម្មនេះផ្តល់នូវភាពងាយស្រួលក្នុងការប្រើប្រាស់កម្មវិធីស្វែងរកព័ត៌មានតាមរយៈអ៊ិនធឺណេត ដែលអនុញ្ញាតឲ្យ បុគ្គលិកអាចទាញយកឯកសារ និងងាយស្រួលបោះពុម្ពឯកសារ។ លើសពីនេះទៀត ការតភ្ជាប់ អ៊ិនធឺណេតឥតខ្សែជាវិធីងាយស្រួល ដើម្បីភ្ជាប់ទៅកាន់ទូរស័ព្ទដៃក្នុងគោលបំណង ដើម្បីរក្សាទំនាក់ ទំនងជាមួយកម្មវិធី Telegram Senate News និង What App។ ម៉្យាងវិញទៀត សភាមាន ឧបករណ៍ព័ត៌មានវិទ្យាជាមូលដ្ឋានមួយចំនួន ដែលបានផ្តល់នូវការតភ្ជាប់បណ្តាញឥតខ្សែ (wireless) ទៅគ្រប់នាយកដ្ឋានទាំងអស់ ដូច្នេះពួកគេអាចចូលដំណើរការប្រព័ន្ធ អ៊ិនធឺណេតបាន។

- អ៊ិនត្រាណេត របស់ព្រឹទ្ធសភា៖ គឺជាបណ្តាញដោយផ្អែកលើអ៊ិនធឺណេតផ្ទៃក្នុងរបស់សភា ដែលប្រើប្រាស់សម្រាប់តែប្រតិបត្តិការផ្ទៃក្នុង និងអាចចូលដំណើរការបានតែតំណាងរាស្ត្រ និងសមាជិក-សភាប៉ុណ្ណោះ។ បណ្តាញនេះត្រូវបានប្រើដើម្បីចែករំលែកព័ត៌មានផ្ទៃក្នុង។ ទោះយ៉ាងណា អ៊ិនត្រាណេតមិនត្រូវបានប្រើប្រាស់ច្រើននោះទេ។ បុគ្គលិកភាគច្រើនប្រើប្រាស់តេឡេក្រាម(Telegram) ដែលជា កម្មវិធីទូរស័ព្ទដៃមួយសម្រាប់ទំនាក់ទំនងសង្គម ដើម្បីជជែកកំសាន្ត ការហៅចេញជាសារសំឡេង ផ្ញើរូបភាព ឬវីដេអូ និងមុខងារដទៃទៀត។ ការនិយមអ៊ិត្រាណេត ដោយសារតែវាផ្តល់ នូវភាពងាយស្រួល និងឆាប់រហ័ស មិនតម្រូវឱ្យចូលក្នុងគណនេយ្យច្រើនដង អាចត្រូវ បានប្រើប្រាស់បានងាយស្រួល រវាងនាយកដ្ឋាន និងអនុញ្ញាតឱ្យចែករំលែកឯកសារ ដែលមានប្រសិទ្ធិភាព និងឆាប់រហ័ស។ តេឡេក្រាម មិនត្រូវបានបង្កើតឡើងយ៉ាងពិសេស សម្រាប់ប្រើប្រាស់ក្នុងសភានោះទេ តែវាជាកម្មវិធីដែលអាចប្រើបានជាសាធារណៈ។ កម្មវិធីនេះធានាសុវត្ថិភាពដល់សារឯកជន។ ទោះជាយ៉ាងណា end-to-end encryption ជាវិធានការសុវត្ថិភាពមួយ

ដែលធានាបានថា ការផ្ញើព័ត៌មានមិនត្រូវបានឃើញដោយបុគ្គលិកផ្សេងក្នុងតេឡេក្រាម ឬត្រូវបានរក្សាទុកនៅលើបណ្តាញកំពុងដំណើរការ វាគ្រាន់តែជាលក្ខណៈពិសេសដែលត្រូវបានបើក នៅក្នុងការកំណត់ (Setting)។[19]



ឧទាហរណ៍ ការចែករំលែកឯកសាររបស់បុគ្គលិកនៅលើតេឡេក្រាម

- បណ្ណាល័យព្រឹទ្ធសភាៈ បណ្ណាល័យនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវឯកសារព័ត៌មាន ឯកសាររបស់សភាដែលបានបោះពុម្ពផ្សាយ និងសេវាស្រាវជ្រាវជូនតំណាងរាស្ត្រ គណៈកម្មការសភា និងសម្រាប់ពលរដ្ឋសាធារណៈ។ រដ្ឋសភាជាតិ បានបង្កើតបណ្ណាល័យអេឡិចត្រូនិច ចាប់តាំងពីចុងឆ្នាំ២០១៤[20] ខណៈពេលដែលព្រឹទ្ធសភានាពេលថ្មីនេះបានចាប់ផ្តើមដាក់ឲ្យប្រើប្រាស់បណ្ណាល័យអេឡិចត្រូនិច នៅខែមិថុនា ឆ្នាំ២០១៦។ បណ្ណាល័យអេឡិចត្រូនិចរបស់ព្រឹទ្ធសភា[21] គឺជាឧបករណ៍ថ្មីបំផុត ដែលបានរួមចំណែកដល់សមិទ្ធិផល និងប្រសិទ្ធភាព នៃមុខងារសភា។ ទោះជាយ៉ាងណា បណ្ណាល័យអេឡិចត្រូនិច គឺសម្រាប់ប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ។ ជាក់ស្តែងបណ្ណាល័យនេះ ក៏ប្រឈមនឹងបញ្ហាសំខាន់ៗមួយចំនួនដូចជាៈ ប្រព័ន្ធគ្រប់គ្រងបែបប្រពៃណី កង្វះខាតធនធានមនុស្ស បុគ្គលិកនៅមានកម្រិត ប្រព័ន្ធគ្រប់គ្រងទិន្នន័យបែបអេឡិចត្រូនិចនៅមានកម្រិត នៅមានចន្លោះប្រហោងក្នុងការចូលរួមជាបណ្តាញដើម្បីផ្លាស់ប្តូរព័ត៌មាន គំនិត និងការអនុវត្តល្អ។

## ៤. បញ្ហាប្រឈមនៃ ICT ក្នុងព្រឹទ្ធសភា

ព្រឹទ្ធសភា មានបញ្ហាប្រឈមមួយចំនួនទៀតទាក់ទងទៅនឹង ការកែលម្អលើការប្រើប្រាស់គេហទំព័រ របស់សភា ក្នុងគោលបំណង ដើម្បីទទួលបានមតិយោបល់ពីប្រជាពលរដ្ឋ។ ទាំងនេះជាបញ្ហាទូទៅ ទាក់ទងនឹងការអភិវឌ្ឍក្នុងព្រឹទ្ធសភាលើវិស័យ ICT៖

- ការឧបត្ថម្ភពីម្ចាស់ជំនួយអន្តរជាតិនៅមានកម្រិត[22]
- មិនមានសម្ភារៈ ICT គ្រប់គ្រាន់
- ថវិកាសម្រាប់វិស័យ ICT និងការគាំទ្រផ្នែកបច្ចេកទេស នៅមានភាពខ្វះខាត និង
- ធនធានមនុស្សផ្នែក ICT មិនគ្រប់គ្រាន់

គេហទំព័រព្រឹទ្ធសភា ផ្តល់ព័ត៌មាន និងការទំនាក់ទំនងតែមួយផ្លូវ[23] តាមរយៈ ICT ពីសភាផ្ទាល់ទៅកាន់ប្រជាពលរដ្ឋ[24]។ ប្រជាពលរដ្ឋក៏ចង់ទទួលបានឱកាស ដើម្បីបញ្ចេញទស្សនៈរបស់ខ្លួន និងចូលរួមជាមួយសមាជិកសភារបស់ពួកគេលើបញ្ហាប្រទេសជាតិ។ កង្វះខាតនៃការសម្របសម្រួល និងហេដ្ឋារចនា-សម្ព័ន្ធICTនៅក្នុងសភា ក៏ដូចជាចំណេះដឹង ជំនាញរបស់បុគ្គលិក នៅមានកម្រិត ទាក់ទងទៅនឹងកម្មវិធី ICT តម្រូវឲ្យធ្វើការដោះស្រាយបញ្ហាទាំងអស់នេះ។ គេហទំព័រ របស់ព្រឹទ្ធសភា មិនផ្តល់នូវ អាស័យដ្ឋាន

អ៊ីម៉ែល របស់គណៈកម្មការ ឬឧបករណ៍ផ្តល់មតិយោបល់ ឬកម្មវិធីណាមួយសម្រាប់ឲ្យប្រជាពលរដ្ឋធ្វើការដាក់ស្នើជាមតិយោបល់ដោយផ្ទាល់តាមរយៈហាទំព័រ។[25] នេះក៏ជាការលំបាកសម្រាប់សភា ដើម្បីឆ្លើយតបទៅនឹងបរិមាណច្រើននៃអ៊ីម៉ែលពីសាធារណៈជន ដូចនេះ គួរបង្កើតអង្គភាពពិសេសណាមួយដើម្បីដោះស្រាយបញ្ហានេះ។ ឧទាហរណ៍ ស្តីពីការទំនាក់ទំនងពីរបៀប (ផ្តល់ព័ត៌មាន និងទទួលព័ត៌មាន) តាមរយៈ វេទិកាលើបណ្តាញសង្គម។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តួចផ្តើមឲ្យមានការទទួល និងឆ្លើយតបទៅនឹងមតិយោបល់ជាសាធារណៈ និងប្រតិកម្មផ្សេងៗនៅលើគេហទំព័រ Facebook ផ្ទាល់ខ្លួនរបស់គាត់។[26]

## ៥. សេចក្តីសន្និដ្ឋាន

បច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យឆ្លើយឆ្លងនៅក្នុងសភាកម្ពុជា ត្រូវបានធ្វើឲ្យប្រសើរឡើង ជាមួយនឹងប្រព័ន្ធសន្តិសុខព័ត៌មាន។ តាមរយៈប្រព័ន្ធនេះ គឺអាចផ្តល់ជូននូវព័ត៌មានផ្សេងៗដែលទាក់ទងនៅក្នុងប្រទេស ក៏ដូចជាសភា ដើម្បីសម្រួល ដល់ការទំនាក់ទំនងពីរបៀបរវាង សភា និងប្រជាពលរដ្ឋ។[27] ព្រឹទ្ធសភា អាចនឹងពិចារណាក្នុងការពង្រឹងការប្រើប្រាស់ ICT នៅក្នុងសភាដូចជា៖ ការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ICTលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍធនធានមនុស្ស ពង្រឹងមុខងារ បណ្ណាល័យអេឡិចត្រូនិច ធ្វើឲ្យប្រសើរឡើងវិញនូវជំនាញបច្ចេកទេសរបស់បុគ្គលិកICT ពង្រឹងការគ្រប់គ្រងទិន្នន័យដើម្បីធ្វើឲ្យមុខងារ សភា កាន់តែមានប្រសិទ្ធភាព ជឿទុកចិត្ត និងតម្លាភាព។ លើសពីនេះទៀត វិស័យ ICT ក្នុងព្រឹទ្ធសភា អាចត្រូវបានធ្វើឲ្យប្រសើរឡើងជាងមុន តាមរយៈការបំពាក់គ្រឿងបរិក្ខាបន្ថែម និងបង្កើនទំហំថវិកា សម្រាប់ការលើកកម្ពស់ ICT។

# ឯកសារយោង

[1] Royal Government of Cambodia. (2014). *National Strategic Development Plan 2014-2018*. p,158. Available at http://cambodia.unfpa.org/sites/asiapacific/files/pub-pdf/NSDP2014-2018.pdf [Accessed on August 20, 2016]
[2]TU. (2016).*WSIS Forum: Outcome Document: WSIS Action Lines: Supporting the Implementation of the SDGs [online]*. Available at https://www.itu.int/net4/wsis/forum/2016/Content/documents/outcomes/WSISForum2016%E2%80%94ForumTrack-Outcomes.pdf [Accessed on July 14, 2016]
[3] Santo (2009) *The Senate Library Enhancing its Research Services to the Senator and Secretrariat Staff*. World e-Parliament Conference. Washington DC, US. pp,1-2.
[4] United Nations. (2012).*Handbook Information and Communication Techonology in Parliamentary Librarries.New York, United Nations*
[5]Nida, H. and Savuth, S. (2016). *Information and Communication Technology in the Senate* S. Sa.
[6] Royal Government of Cambodia. (2013). *Rectangular Strategy-Phase III 2013.* pp,27-28 Available at http://faolex.fao.org/docs/pdf/cam145560.pdf [Accessed on August 20, 2016]
[7] Korea International Cooperation Agency. (2014). *Cambodian ICT Masterplan 2020*. pp13-17. Available at http://www.trc.gov.kh/wp-content/uploads/2015/03/Cambodian-ICT-Masterplan-2020.pdf [Accessed on August 20, 2016]
[8] Japan International Cooperation Agency. (2009). *National ICT Policy: Policy Proposal for the Government of Cambodia.* Available at http://www.jica.go.jp/project/cambodia/0609376/04/pdf/01_policy_e.pdf [Accessed on August,22 2016]
[9] Telecommunication Regulation of Cambodia. (2015). *Law on Telecommunications.* Available at http://www.trc.gov.kh/wp-content/uploads/2016/03/Law-on-Telecommunicaiton-in-Eglish-Unofficial-Translation.pdf [Accessed on August 22, 2016]
[10] Telecommunication Regulation of Cambodia. *Law on Management of Radio Communication.* Available at https://www.trc.gov.kh/laws/ [Accessed on August 22, 2016]
[11] Sithi. *Cybercrime Law*. Available at http://sithi.org/admin/upload/law/Cybercrime%20Law.pdf [Accessed on August 22, 2016]
[12] Ministry of Commerce. (2003). *Law on the Copyright and Related Right*. Available at http://www.moc.gov.kh/Portals/0/Docs/OfficialDocs/2003%2003%2005th,%20Law%20on%20Copyright%20and%20Related%20Rights%20(Khmer).pdf [Accessed on August 22, 2016]
[13] For example, in the National Election in 2013, the internet and social media especially Facebook are changing the dynamics of election politics as many Cambodian's youths showed their interest in political issues and freely express their views.
[14] Sophat, S. (2013). *Social Media's Growing Influence on Cambodia Pllitics.* East-West Center. Number 222. pp,1-2
[15] Nida, H. and Savuth, S. (2016). Information and Communication Technology in the Senate S. Sa.
[16] Senate website. Available at http://www.senate.gov.kh/home/index.php?lang=km [Accessed on 14 July 2016]
[17] You can download it from AppStore both in (IOS and Android) just search for "Senate News".
[18] Use to find out what level the respondent can browse the Web using links and URLs (web addresses) and use of search engines and commands such as download and print.
[19] Official telegram website: https://telegram.org/faq#security, accessed on September 2nd, 2016
[20] National Assembly. *e-library*. Available at http://www.national-assembly.org.kh/group-article/81 [Accessed on July 14, 2016 ]
[21] Senate website. *e-library*. Available at http://www.elibrary.senate.gov.kh/ [Accessed on July 29, 2016 ]
[22] Nida, H. and Savuth, S. (2016). Information and Communication Technology in the Senate S. Sa.
[23] Parliamentary is providing information to citizen but did not get any feedback from the citizen
[24] Nida, H. and Savuth, S. (2016). Information and Communication Technology in the Senate S. Sa.
[25] National Assembly and Senate's Website.

[26]Samdech Hun Sen, Cambodia Prime Minister ( Facebook page)
[27]Inter Parliamentary Union. (2016). *World e-Parliament Report 2016.* p,55. Available at http://www.ipu.org/pdf/publications/eparl16-en.pdf [Accessed on July 29, 2016 ]